


# គឺជាអ្វី?

# មានផលប៉ះពាល់អ្វីខ្លះ?

# ត្រូវធ្វើបែបណាចំពោះប្លាស្ទីក?

**ទំនាក់ទំនង:** អាគារ ៣A ផ្លូវលេខ ១៦៩ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ
ទូរស័ព្ទលេខ: (៨៥៥)-១៦ ៧៣៨ ៤០៣
អ៊ីម៉ែល admin@cambodiacleancity.gov.kh គេហទំព័រ www.cambodiacleancity.gov.kh

## តើអ្នកដឹងទេ?

ថង់ប្លាស្ទិកត្រូវបានមើលឃើញថានៅរាយប៉ាយតាមដងផ្លូវ ឬនៅតាមវាល ជួនកាលនៅតាមមែកឈើដែលប៉ះពាល់សោភ័ណភាពរបស់ទីក្រុង។

ផលិតផលថង់ប្លាស្ទិក គឺជាបញ្ហាប្រឈមមួយយ៉ាងសំខាន់ចំពោះបរិស្ថាន និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងប៉ះពាល់ដល់ជីវិតសត្វ និងជីវៈចម្រុះផងដែរ។



# ថង់ប្លាស្ទីកគឺជាអ្វី?

ថង់ប្លាស្ទីកជាវត្ថុមួយដែលមិនរលាយក្នុងទឹកទេ។



ថង់ប្លាស្ទីកចំណាយរយៈពេល ១០០០ ឆ្នាំដើម្បីរលាយ។

ថង់ប្លាស្ទីកភាគច្រើនត្រូវបានផលិតចេញពីសារធាតុ **"ប៉ូលីយ៉ែតទីឡែន"** (Polyethylene) ដែលជាជាតិគីមីពុលមួយបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពរបស់មនុស្ស។



# ថង់ប្លាស្ទីកមានផលប៉ះពាល់អ្វីខ្លះ?



បញ្ហាថង់ប្លាស្ទីក គឺជាបញ្ហាប្រឈមរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ព្រោះថារាល់ទំនិញ ឬវត្ថុភាគច្រើនសុទ្ធតែប្រើប្រាស់ថង់ប្លាស្ទីកក្នុងការវេចខ្ចប់។

## ផលប៉ះពាល់ចំពោះបរិស្ថាន



ថង់ប្លាស្ទីកត្រូវបានមើលឃើញថាមាននៅរាយប៉ាយតាមដងផ្លូវ ឬនៅតាមមែកឈើ ដែលធ្វើឱ្យប៉ះពាល់ដល់សោភ័ណភាពទីក្រុង។

ថង់ប្លាស្ទិកជាវត្ថុមួយដែលមិនរលាយក្នុងទឹកទេ ដូច្នេះវាជាឧបសគ្គមួយរារាំងចរន្តទឹកហូរ រាំងស្ទះដល់ប្រព័ន្ធបង្ហូរទឹកកង្វក់ដែលអាចបង្កជាជំនន់ទឹកភ្លៀងពេលប្រព័ន្ធលូស្ទះ។



ការទុកដាក់សំរាម និងថង់ប្លាស្ទិកមិនបានត្រឹមត្រូវធ្វើឲ្យបាត់បង់សោភ័ណ-ភាពនៅតាមទីរមណីយដ្ឋាននានា។





## ផលប៉ះពាល់ចំពោះទីលានចាក់សំរាម

ថង់ប្លាស្ទីកភាគច្រើនត្រូវបានយកទៅចាក់បង្គរនៅតាមទីលានចាក់សំរាមដែលជាកត្តានាំឲ្យការប្រើប្រាស់ទីលានចាក់សំរាមមិនមាននិរន្តភាព។





ថង់ប្លាស្ទីកចំណាយរយៈពេល ១០០០ ឆ្នាំដើម្បីរលាយ ប៉ុន្តែវានៅតែមានការបំពុលយ៉ាងធ្ងន់ធ្ងរចំពោះទឹក ដី និងបរិស្ថានជុំវិញ។

# ផលប៉ះពាល់ចំពោះទឹក

ថង់ប្លាស្ទីកបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើទឹក ព្រោះវាជាធាតុមួយដែលមិនរលាយក្នុងទឹក ដែលអាចបង្កជាការលំបាកដល់ការធ្វើចរាចរណ៍លើផ្ទៃទឹករបស់ប្រជាពលរដ្ឋ។



វាក៏រាំងស្ទះដល់ការផ្លាស់ទីរបស់សត្វ និងជីវៈចំរុះនៅក្នុងទឹកផងដែរ។



## ផលប៉ះពាល់ចំពោះសត្វ

ការចោលថង់ប្លាស្ទីកតាមដងស្ទឹង ទន្លេ និងសមុទ្រ គឺជាមូលហេតុចំបងដែលធ្វើឲ្យសត្វងាប់ ព្រោះថាសត្វទាំងអស់នោះអាចនឹងយកថង់ប្លាស្ទីកដែលមាននៅក្នុងទឹកធ្វើជាចំណី។



ជារៀងរាល់ឆ្នាំ មានត្រី បក្សី និងសត្វរាប់លានក្បាលងាប់ដោយសារស៊ីថង់ប្លាស្ទីកជាអាហារ។





# ផលប៉ះពាល់ចំពោះមនុស្ស

ថង់ប្លាស្ទីកភាគច្រើនត្រូវបានផលិតចេញពីសារធាតុ **"ប៉ូលីយ៉ែតទីឡែន"** (Polyethylene) ដែលជាជាតិគីមីពុលមួយបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរដល់សុខភាពរបស់មនុស្ស។ សារធាតុគីមីដែលមាននៅក្នុងថង់ប្លាស្ទីកអាចបណ្តាលឲ្យ "ហ៊ែរន" របស់មនុស្សប្រែប្រួល និង "ក្រូម៉ូស៊ូម" ត្រូវបានបំផ្លាញ។

ចំពោះទារកវិញ ជាតិគីមីនេះអាចបណ្តាលឲ្យប្រព័ន្ធភាពស៊ាំនៃរាង្គកាយចុះខ្សោយ ដែលធ្វើឲ្យងាយស្រួលក្នុងការឆ្លងជំងឺផ្សេងៗ។



## ត្រូវធ្វើបែបណាចំពោះប្លាស្ទិក?

មានវិធានការមួយចំនួនក្នុងការទប់ស្កាត់ និងការកាត់បន្ថយគ្រោះថ្នាក់នៃថង់ប្លាស្ទិកចំពោះបរិស្ថានដូចជា ៖

**១-កាត់បន្ថយការវេចខ្ចប់ដោយថង់ប្លាស្ទិក៖** ដោយប្រើប្រាស់ថង់ប្លាស្ទិកឱ្យបានតិចបំផុតតាមដែលអាចធ្វើបាន។



**២-រួមគ្នាប្រើប្រាស់ផលិតផលដែលធ្វើពីក្រណាត់ ឬស្លឹកឈើ** (ស្លឹកចេក ឬស្លឹកឈូក) សម្រាប់ជំនួសឱ្យការប្រើប្រាស់ថង់ប្លាស្ទិក។





**៣-ប្រើប្រាស់ឡើងវិញនូវថង់ប្លាស្ទីក**ដែលនៅល្អស្អាត។




៤-ប្រើប្រាស់ថង់បរិស្ថាន (Eco-bag)។




**៥-ការកែច្នៃថង់ប្លាស្ទីក** ជាវត្ថុសិល្បៈជំនួសឲ្យការបោះចោលទៅទីលានចាក់សំរាម។





**៦-ជៀសវាងការបោះចោលថង់ប្លាស្ទីកនៅតាមទីសាធារណៈ** ឬនៅតាមទីវាល ព្រោះវាអាចធ្វើឲ្យប៉ះពាល់ដល់សោភ័ណភាព។



**៧-លើកទឹកចិត្តដល់ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន សណ្ឋាគារក្នុងការប្រើប្រាស់ស្លឹក** (ស្លឹកឈូក ស្លឹកចេក -ល-) សម្រាប់វេចខ្ចប់ម្ហូបអាហារ ដើម្បីកាត់បន្ថយការប្រើប្រាស់ថង់ប្លាស្ទីក។



បញ្ហាថង់ប្លាស្ទីក គឺជាបញ្ហាប្រឈមរបស់ប្រទេសកម្ពុជានាពេលបច្ចុប្បន្ន ព្រោះថារាល់ទំនិញ ឬវត្ថុទាំងអស់សុទ្ធតែប្រើប្រាស់ថង់ប្លាស្ទីក ក្នុងការវេចខ្ចប់។ ប៉ុន្តែប្រជាពលរដ្ឋទាំងអស់ពុំបានពិចារណាពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃថង់ប្លាស្ទីក មកលើសុខភាពរបស់ពួកគាត់ទេ។ ដូច្នេះ វាគួរតែដល់ពេលវេលាដែលចាប់ផ្តើម យកចិត្តទុកដាក់ពីសុខភាព និងពីបរិស្ថានរបស់ពួកយើងនៅថ្ងៃនេះ ដើម្បីអនាគត ដ៏ល្អរបស់ក្មេងជំនាន់ក្រោយនៅថ្ងៃស្អែក។

## សូមនិយាយថា "ទេ! ចំពោះប្លាស្ទីក"



**រៀបចំដោយ:**

MINISTRY OF TOURISM

**គាំទ្រដោយ:**

CAMBODIA

ស្រាបៀរ កម្ពុជា

**ឧបត្ថម្ភដោយ:**

CAMBODIA AIRPORTS

ACLEDA Bank Plc.

SOKHA HOTELS & RESORTS

CINTRI

Coca-Cola

HUNNAREACH DEVELOPMENT

EnviroCam